# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការកំពូល និងមហាអយ្យការ**

**អមតុលាការកំពូល**

លេខ ០៣ តកក.នសក

# ប្រធានតុលាការកំពូល

**<u>ផ្ញើជូន</u>**

## លោកជំទាវប្រធានសាលាឧទ្ធរណ៍

## លោកប្រធានតុលាការគ្រប់ខេត្ត ក្រុង

**<u>កម្មវត្ថុ</u>:** អំពីការប្រើប្រាស់សិទ្ធិឆ្លើយតប ឬ កែតម្រូវចំពោះអត្ថបទសារព័ត៌មានទាំងឡាយ ដែលចុះផ្សាយខុសពីការពិតទាក់ទងនឹងរឿងក្តីរបស់តុលាការ ។

**<u>យោង</u>:** មាត្រា ៧,១០ និង១៣ នៃច្បាប់ស្តីពីរបបសារព័ត៌មាន

-មាត្រា ៦២ និង៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល

កន្លងមកតុលាការកំពូលបានកត់សម្គាល់ឃើញថា លោកជំទាវ ឯកឧត្តម លោក លោកស្រីជាចៅក្រមនិងព្រះរាជអាជ្ញា បានខិតខំប្រឹងប្រែងយ៉ាងច្រើនឥតគណនា ដើម្បីដោះស្រាយរឿងក្តីស្វែងរកយុត្តិធម៌ជូនពលរដ្ឋស្លូតត្រង់ និងការពារសណ្តាប់ធ្នាប់ សន្តិសុខ សុវត្ថិភាពសង្គម ក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូលធ្វើអោយសង្គមជាតិយើងមានការរីកចម្រើន ជាបន្តបន្ទាប់តាមបែបនីតិរដ្ឋ ។

ប៉ុន្តែជាការគួរអោយសោកស្តាយណាស់ ដែលការខិតខំប្រឹងប្រែង់ទាំងអម្បាលមាណ ព្រមទាំងលទ្ធផលដ៏ល្អប្រសើររបស់យើងពុំត្រូវបានបណ្តាញសារព័ត៌មានយកមកចុះផ្សាយ ផ្ទុយទៅវិញស្ទើរតែរាល់ថ្ងៃយើងតែងសង្កេតឃើញនៅលើទំព័រសារព័ត៌មាន សុទ្ធតែជាព័ត៌មានអាក្រក់ៗពីចៅក្រម និងព្រះរាជអាជ្ញាយើង ។ តុលាការកំពូលតែងបានយកចិត្តទុកដាក់ស្រាវជ្រាវលើគ្រប់ករណីដែលបានចុះផ្សាយលើសារព័ត៌មានទាំងនោះ ។ លទ្ធផលបង្ហាញអោយឃើញថាមានតព័ត៌មានតិចតួចបំផុតដែលបានចុះផ្សាយតាមការពិត រីឯព័ត៌មានភាគច្រើនគឺផ្សាយខុសពីការពិតដោយស្តាប់សម្តីតែភាគីម្ខាង ។ ប្រការទាំងនេះបានធ្វើអោយមជ្ឈដ្ឋានប្រជាពលរដ្ឋយល់ច្រលំទាំងស្រុង និងអស់ជំនឿលើស្ថាប័នតុលាការនៅកម្ពុជា ហើយសាម៉ីខ្លួនដែលរងគ្រោះដោយអត្ថបទសារព័ត៌មាននោះពុំដែលសុំកែតម្រូវ ឬ ឆ្លើយតបទេ ដោយលើកមតិមិនចង់មានទំនាស់ជាមួយអ្នកកាសែត ឬថាកុំរវល់ជាមួយអ្នកកាសែត ដែលទស្សនៈបែបនេះគឺជាការខុសឆ្គង បណ្តោយអោយគេជាន់ឈ្លីកិត្តិយសរបស់តុលាការ ដោយអយុត្តិធម៌ ។

អាស្រ័យហេតុនេះ ចាប់ពីពេលនេះតទៅ សូមលោកជំទាវ ឯកឧត្តម លោក លោកស្រី ដែលជាចៅក្រម ព្រះរាជអាជ្ញា ប្រើប្រាស់សិទ្ធិរបស់ខ្លួនធ្វើការឆ្លើយតប ឬ កែតម្រូវនូវព័ត៌មានមិនពិតទាំងនោះតាមមាត្រា១០ នៃច្បាប់ស្តីពីរបបសារព័ត៌មាន ។ ប៉ុន្តែអត្ថបទឆ្លើយតប ឬកែតម្រូវ គប្បីសរសេរអោយបានខ្លីនិយាយអោយចំបញ្ហាអោយងាយយល់ និងមានខ្លឹមសារគ្រប់គ្រាន់ ដោយចៀសវាងនូវពាក្យ ឬ ខ្លឹមសារណាដែលមានន័យផ្ទាញ់ផ្ទាល ឬហិង្សា ឬបង្កជំលោះ ឬសំដែងអោយឃើញនូវភាពមិនថ្លៃថ្នូររបស់ខ្លួនជាចៅក្រម ។

ក្នុងករណីដែលសារព័ត៌មាននោះពុំព្រមចុះផ្សាយនូវអត្ថបទកែតម្រូវ ឬ ឆ្លើយតបទេ ឬ នៅតែបន្តផ្សាយបំភ្លើសថែមទៀតចៅក្រម ឬ ព្រះរាជអាជ្ញាដែលរងគ្រោះមានសិទ្ធិប្តឹងទៅព្រះរាជអាជ្ញាសារព័ត៌មាន និងច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

ខ្ញុំសង្ឃឹមថា លោកជំទាវ ឯកឧត្តម លោក និង លោកស្រី ដែលជាចៅក្រម និងព្រះរាជអាជ្ញាទាំងអស់យកចិត្តទុកដាក់កែតម្រូវ ឬ ឆ្លើយតបអោយទាន់ពេលវេលា ដើម្បីអោយមតិសាធារណៈយល់ច្បាស់អំពីករណីនីមួយៗដែលត្រូវបានចោទឡើងនៅក្នុងសារព័ត៌មានទាំងនោះ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៥

<u>ចម្លងជូន</u>

-ក្រសួងយុត្តិធម៌
-ក្រសួងព័ត៌មាន
-លេខាធិការដ្ឋាន ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម
-មហាអយ្យការអមតុលាការកំពូល
-មហាអយ្យការអមសាលាឧទ្ធរណ៍
-អយ្យការអមតុលាការគ្រប់ ខេត្ត-ក្រុង
-ឯកសារ

**ឌិត មុន្ទី**